# ព័ត៌មានអំពីជំងឺ COVID–19

ការធ្វើតេស្ត និងការចាក់វ៉ាក់សាំង

781-595-7747



## ការចាក់វ៉ាក់សាំង

**តើវ៉ាក់សាំងនឹងធ្វើឲ្យខ្ញុំឈឺឬទេ?**

- ទេ អ្នកនឹងមិនកើតជំងឺ COVID-19 ពីវ៉ាក់សាំងទេ។ អ្នកអាចនឹងមានផលរំខានខ្លះ ក្រោយពេលចាក់លើកទីមួយ ឬលើកទីពីរ ប៉ុន្តែអាការៈទាំងនោះនឹងបាត់ទៅវិញនៅពីរ ឬបីថ្ងៃក្រោយ។ បើវាមិនបាត់ទេ សូមទូរសព្ទទៅវេជ្ជបណ្ឌិតរបស់អ្នក។
- ផលរំខានដែលតែងកើតឡើង មានដូចជា ឈឺដៃ (នៅកន្លែងចាក់) ក្តៅខ្លួន ឈឺសាច់ដុំ ឈឺក្បាល។

**ប្រសិនបើខ្ញុំចាក់វ៉ាក់សាំងហើយ តើខ្ញុំនៅតែត្រូវពាក់ម៉ាស់ឬទេ?**

- ពាក់។ ព្រោះមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែទទួលបានវ៉ាក់សាំងទេ ហើយដោយសារនៅមានជំងឺ COVID-19 ប្រភេទថ្មីៗដែលកំពុងឆ្លង ដូច្នេះអ្នកគួរតែពាក់ម៉ាស់ រក្សាគម្លាតសុវត្ថិភាព និងលាងដៃរបស់អ្នក។

**តើព័ត៌មានដែលខ្ញុំផ្តល់ឲ្យនឹងត្រូវបានប្រើប្រាស់ដោយសេវាកម្មអន្តោប្រវេសន៍ឬទេ?**

- ទេ។ ព័ត៌មានដែលអ្នកផ្តល់ឲ្យនឹងមិនត្រូវបានប្រើប្រាស់ដោយសេវាកម្មអន្តោប្រវេសន៍ទេ ឬសម្រាប់រដ្ឋតាមដានអ្នក សមាជិកគ្រួសាររបស់អ្នក ឬអ្នកជិតខាងរបស់អ្នកទេ។ ព័ត៌មានទាំងនេះគឺសម្រាប់ជួយយើងឲ្យដឹងថា នរណាខ្លះបានទទួលវ៉ាក់សាំងហើយ និងនរណាមិនទាន់បានទទួលវ៉ាក់សាំងនៅឡើយ។

**ណាត់ពេលដើម្បីទទួលវ៉ាក់សាំងរបស់អ្នក**

*បើកទូលាយសម្រាប់អ្នករស់នៅក្នុងរដ្ឋ Massachusetts*

https://www.lchcnet.org/covid-19-vaccine-scheduling

**ព័ត៌មានបន្ថែម៖**

https://www.lchcnet.org/covid-19-vaccine-information

**គ្លីនិកចាក់វ៉ាក់សាំងចល័ត៖**
**យើងនឹងយកវ៉ាក់សាំងទៅអ្នក!**

https://www.lchcnet.org/mobile-vaccination-program

- សម្រាប់អាជីវកម្ម អង្គការសហគមន៍ កន្លែងថ្វាយបង្គំ
- នៅទីតាំងរបស់អ្នក ឬសហការជាមួយអង្គការមួយទៀត
- យើងប្តេជ្ញាចិត្តធ្វើឲ្យវាដំណើរការជាមួយស្ថាប័នរបស់អ្នក

*មិនចាំបាច់មានរថយន្តសម្រាប់ធ្វើតេស្ត ឬចាក់វ៉ាក់សាំងទេ។ អ្នកមិនចាំបាច់ត្រូវតែជាអ្នកជំងឺរបស់ LCHC ឬមានការធានារ៉ាប់រងសុខភាពទេ។*

## ការធ្វើតេស្ត

**ហេតុអ្វីខ្ញុំត្រូវធ្វើតេស្ត?**

- ការតាមដានអត្រាកើតជំងឺ COVID-19 នឹងជួយយើងឲ្យអាចបើកសហគមន៍របស់យើងឡើងវិញបានដោយសុវត្ថិភាព និងការពារមនុស្សដែលយើងស្រលាញ់។
- ចំនួនវ៉ាក់សាំងគឺមានកំណត់ ហើយមិនទាន់មានសម្រាប់គ្រប់គ្នានៅឡើយ។
- វ៉ាក់សាំងមិនមានប្រសិទ្ធភាព 100% ទេ ទោះយ៉ាងណាវាជួយយើងបានយ៉ាងច្រើន និងមានសុវត្ថិភាពណាស់។
  - ✓ នរណាក៏អាចធ្វើតេស្តបានដែរ ទាំងមនុស្សពេញវ័យ និងកុមារ
  - ✓ អ្នកមិនចាំបាច់មានការធានារ៉ាប់រងសុខភាពទេ
  - ✓ អ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍ទេ

**ពិនិត្យមើលម៉ោងដែលយើងធ្វើតេស្តដោយឥតគិតថ្លៃ៖**

https://www.lchcnet.org/covid-19-testing-information

*សូមស្វាគមន៍ចំពោះការដើរចូលមកធ្វើតេស្ត។*

@lynn.communityhealthcenter | Lynn Community Health Center | @LynnCHC